**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានព័ត៌មាន

# សេចក្តីបំភ្លឺ

នាពេលថ្មីៗនេះ មានការផ្សព្វផ្សាយជាមួយការបកស្រាយមួលបង្កាច់ខុសពីការពិត ពាក់ព័ន្ធលិខិតរបស់ ឯកឧត្តម ទុយ រី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន ផ្ញើជូនឯកឧត្តម SAKAGUCHI Naoto សមាជិកសភាជាន់ទាបជប៉ុន ជម្រាបជូនអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដែលអាចធ្វើឱ្យមានការយល់ច្រឡំលើខ្លឹមសារលិខិតរបស់ឯកឧត្តមឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន។

អ្នកនាំពាក្យរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមធ្វើការបំភ្លឺដូចខាងក្រោមៈ

- កម្ពុជាតែងតែវាយតម្លៃខ្ពស់ពីការជួយគាំទ្រពីសំណាក់ប្រជាជនជប៉ុនក្នុងរយៈកាលកន្លងមក ហើយទំនាក់ទំនងដ៏កក់ក្តៅ និងមានការវិវឌ្ឍទៅមុខជាវិជ្ជមានជានិច្ច បានធ្វើឱ្យប្រទេសទាំងពីរសម្រេចបាននូវភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា បានចាត់ទុកជប៉ុនជាមិត្តដែលមិនអាចខ្វះបាន ដែលជានិច្ចកាលបន្តផ្តល់ជំនួយគ្រប់វិស័យដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា។
- លិខិតរបស់ឯកឧត្តមឯកអគ្គរាជទូត ទុយ រី ជូនសមាជិកសភាជប៉ុន SAKAGUCHI Naoto (លិខិតដើម និងអត្ថបទបកប្រែជាភាសាខ្មែរមានជូនភ្ជាប់) គឺជាការពន្យល់បកស្រាយបំភ្លឺអំពីជំហរពីការពិតជាក់ស្តែងស្តីពីស្ថានភាពសិទ្ធិមនុស្ស និងប្រជាធិបតេយ្យនៅកម្ពុជា ហើយនិងជាសំណូមពរតាមបែបលក្ខណៈការទូត ដោយមិនមានបង្កប់នូវន័យគំរាមកំហែង និងប៉ះពាល់ដល់កិត្តិយសរបស់ឯកឧត្តម SAKAGUCHI Naoto ទេ។ ដូចបញ្ជាក់ច្បាស់រួចហើយនៅក្នុងលិខិតរបស់ឯកឧត្តមឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន ផ្ញើជូនឯកឧត្តមតំណាងរាស្ត្រ SAKAGUCHI Naoto គឺមិនមានពាក្យណាមួយក្នុងលិខិតនេះ មានបង្កប់នូវការគំរាមកំហែងឡើយ ហើយលិខិតនេះត្រូវបានស្ថានទូតផ្ញើជូនឯកឧត្តម SAKAGUCHI

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

Naoto តាមប្រកការទូត ដែលបង្ហាញយ៉ាងច្បាស់ពីការផ្តល់តម្លៃ និងការគោរពចំពោះឯកឧត្តម SAKAGUCHI Naoto។

- ប៉ុន្តែ លិខិតបកស្រាយបំភ្លឺរបស់ឯកឧត្តមឯកអគ្គរាជទូត ទុយ រី ត្រូវបានជនអគតិមួយចំនួនតូចយកមកធ្វើអាជីវកម្មនយោបាយ បកប្រែបំផ្លើស ធ្វើឱ្យមានការយល់ច្រឡំថា ឯកឧត្តម ទុយ រី បានគំរាមកំហែងសមាជិកសភាជប៉ុន។ នេះជាចេតនាមួលបង្កាច់ និងបំណងបង្ខូចកេរ្តិ៍ឈ្មោះប្រទេសកម្ពុជាយ៉ាងច្បាស់ និងបង្កឱ្យមានការយល់ច្រឡំពីសំណាក់ជនមួយចំនួនតូច ដែលចង់បំផ្លាញទំនាក់ទំនងល្អ និងកក់ក្តៅកម្ពុជា-ជប៉ុន ហើយដែលនៅដំណាច់ខែឧសភានេះ សម្តេចធិបតីនាយករដ្ឋមន្ត្រីនឹងអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ទៅបំពេញទស្សនកិច្ចការងារផ្លូវការនៅប្រទេសជប៉ុន ។
- ជាថ្មីម្តងទៀត កម្ពុជាវាយតម្លៃខ្ពស់ចំពោះមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរ ហើយកម្ពុជាតាំងចិត្តធ្វើការដោយការគោរពគ្នាទៅវិញទៅមកជាមួយជប៉ុនក្នុងការដោះស្រាយការព្រួយបារម្ភណាមួយ ដែលអាចប៉ះពាល់ដល់ផលប្រយោជន៍ប្រទេសទាំងពីរ។

ថ្ងៃអាទិត្យ ១៤ រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២៥

តូក្យូ ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២៥

ឯកឧត្តម SAKAGUCHI Naoto

សមាជិកសភាជាន់ទាបជប៉ុន

ទីក្រុងតូក្យូ

ឯកឧត្តម

ខ្ញុំសូមលើកយកការអត្ថាធិប្បាយថ្មីៗរបស់ ឯកឧត្តម ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា ដូចដែលបានលើកឡើងក្នុងអំឡុងពេលនៃកិច្ចប្រជុំគណៈកម្មាធិការកិច្ចការបរទេស ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៥ នៅក្នុងសភាជាន់ទាបប្រទេសជប៉ុន។ ខណៈដែលយើងបានដឹង និងយល់ពីទស្សនៈនានាលើបញ្ហាដ៏សំខាន់នេះ ជាការចាំបាច់ណាស់ដែលវាឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវលើការពិតរបស់កម្ពុជា និងកិច្ចខំប្រឹងប្រែងដែលកំពុងបន្ត ក្នុងការជម្រុញអភិបាលកិច្ចប្រជាធិបតេយ្យ និងការគាំពារសិទ្ធិមនុស្ស។

វាបានទាញការយកចិត្តទុកដាក់របស់ខ្ញុំ ដែលការយល់ដឹងរបស់ ឯកឧត្តម អាចមានឥទ្ធិពលជាចម្បងដោយការចូលរួមជាមួយបុគ្គលខ្មែរមួយចំនួនរស់នៅក្នុងប្រទេសជប៉ុនក្នុងនោះ មានអ្នកខ្លះបានចូលរួមយ៉ាងសកម្ម ក្នុងបាតុកម្មប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជា។ ដោយមើលឃើញពីចំណុចនេះ និងក្នុងស្មារតីនៃការសន្ទនាក្នុងន័យស្ថាបនា និងការយល់ដឹងពីគ្នាទៅវិញទៅមករវាងប្រទេសយើងទាំងពីរ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមផ្តល់ការបំភ្លឺជាក់ស្តែង ដើម្បីដោះស្រាយបញ្ហានានា ដែលយើងជឿថា មានការយល់ច្រឡំ ខ្វះភស្តុតាងគ្រប់គ្រាន់ និង មានហេតុផលនយោបាយ។

១. ការរំលាយគណបក្សសង្គ្រោះជាតិកម្ពុជា

ការរំលាយគណបក្សសង្គ្រោះជាតិ ជាបញ្ហាដែលមានឫសគល់ជាយូរមកហើយ។ តុលាការកំពូលបានរំលាយគណបក្សសង្គ្រោះជាតិកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយអនុលោមតាមមាត្រា៦ ៧ និងមាត្រា៤៤ នៃច្បាប់ស្តីពីគណបក្សនយោបាយ។ ការសម្រេចចិត្តនេះ មិនមានន័យថា រដ្ឋាភិបាលប៉ុនប៉ង រឹតត្បិតប្រព័ន្ធនយោបាយប្រជាធិបតេយ្យសេរីនិយម ពហុនិយមទេ។សម្រាប់ព័ត៌មានលម្អិត សូមអានឯកសារភ្ជាប់ស្តីពីការរំលាយគណបក្សសង្គ្រោះជាតិ។

២. ការបោះឆ្នោតទូទៅឆ្នាំ ២០១៨

ប្រទេសកម្ពុជាប្រកាន់ខ្ជាប់នូវរបបប្រជាធិបតេយ្យសេរីពហុបក្ស ដែលបានបង្ហាញយ៉ាងច្បាស់ដោយចំនួនគណបក្សនយោបាយដែលចូលរួមការបោះឆ្នោតសកលចំនួន ៥ដងៈ៤ នៅឆ្នាំ១៩៩៣ ៧ នៅឆ្នាំ១៩៩៨ ៧ នៅឆ្នាំ២០០៣ ១១នៅឆ្នាំ

២០០៨ ៨ នៅឆ្នាំ ២០១៣ ២០ នៅឆ្នាំ២០១៨ និង ១៨ នៅឆ្នាំ ២០២៣។ សម្រាប់ឆ្នាំ ២០១៨ មានគណបក្សនយោបាយចំនួន២០ ដែលបានចុះបញ្ជីជាផ្លូវការ។ ក្នុងដំណើរការបោះឆ្នោតឃុំសង្កាត់ និងសភានៅឆ្នាំ២០២៣ និង ២០២៤ សិទ្ធនយោបាយស៊ីវិលត្រូវបានពង្រីកយ៉ាងទូលំទូលាយ។ ការបោះឆ្នោតសកលឆ្នាំ២០២៣ អ្នកចូលរួមបោះឆ្នោតមានចំនួនដល់ ៨៤.៥៩% ដើម្បីចូលរួមបោះឆ្នោតជ្រើសរើសគណបក្សនយោបាយមួយក្នុងចំណោមគណបក្សនយោបាយដែលឈរឈ្មោះសរុបចំនួន ១៨ គណបក្ស និងដើម្បីជ្រើសរើសអ្នកដឹកនាំរបស់ពួកគេនៅពេលអនាគត។ ការបោះឆ្នោតត្រូវបានវាយតម្លៃយ៉ាងទូលំទូលាយថា សេរី យុត្តិធម៌ និងគួរឱ្យទុកចិត្ត ដោយអ្នកសង្កេតការណ៍រាប់ពាន់នាក់ ក្នុងនោះមាន ៣៣៣នាក់ មកពីបរទេស ដែលតំណាងឱ្យ ៦៥ ប្រទេសផ្សេងៗគ្នា។ ការបោះឆ្នោតព្រឹទ្ធសភា ក៏បានប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងសន្តិភាពផងដែរ ដែលធ្វើការបោះឆ្នោតជាឯកច្ឆ័ន្ទជ្រើសរើស សម្តេចតេជោ ហ៊ុន សែន ជាប្រធានព្រឹទ្ធសភា ដោយសមាជិកព្រឹទ្ធសភាទាំង ៦២ រូប ដែលមានវត្តមានក្នុងសម័យប្រជុំពេញអង្គ។

៣. ចំពោះការមិនពេញចិត្តទាក់ទងនឹង "ការផ្លាស់ប្តូរអំណាចផ្អែកលើគ្រួសារ" វាបានផ្ទុយទៅនឹងការពិត ពីព្រោះអំណាចនៅកម្ពុជាត្រូវបានជ្រើសដោយប្រជាជន តាមបែបរដ្ឋធម្មនុញ្ញ និងប្រជាធិបតេយ្យ។ ការផ្ទេរអំណាច គឺប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ទៅនឹងដំណើរការប្រជាធិបតេយ្យនៅគណបក្ស ការបោះឆ្នោត និងសភា ដូចដែលបានការពារដោយរដ្ឋធម្មនុញ្ញ។

៤. ការអភិវឌ្ឍ និងសន្តិភាពរបស់កម្ពុជា

បទពិសោធន៍របស់កម្ពុជាគឺជាសក្ខីភាពដែលបង្ហាញថា ជម្លោះអាចដោះស្រាយបាន យុត្តិធម៌អន្តរកាលអាចសម្រេចបាន ហើយអតីតតំបន់សង្គ្រាមអាចត្រូវបានប្រែក្លាយទៅជាតំបន់សន្តិភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ។ ការផ្លាស់ប្តូរនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ។ វាជាលទ្ធផលនៃការដឹកនាំប្រកបដោយចក្ខុវិស័យរបស់ សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា។ គោលនយោបាយ "ឈ្នះ-ឈ្នះ" របស់ សម្តេចតេជោ មិនត្រឹមតែបាននាំមកនូវការបញ្ចប់ជម្លោះផ្ទៃក្នុងជាច្រើនទសវត្សរ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចាក់គ្រឹះសម្រាប់ការផ្សះផ្សាជាតិ ស្ថិរភាពយូរអង្វែង និងការអភិវឌ្ឍ សេដ្ឋកិច្ច-សង្គមប្រកបដោយចីរភាព។

វឌ្ឍនភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមដ៏គួរអោយចាប់អារម្មណ៍របស់កម្ពុជា គឺជាការបញ្ជាក់មួយយ៉ាងច្បាស់។ អាយុសង្ឃឹមរស់បានកើនឡើងពីអាយុ ៥៩ឆ្នាំ ក្នុងឆ្នាំ២០០០ ដល់ ៧៦ឆ្នាំ នៅឆ្នាំ២០២១។ មុនពេលជំងឺរាតត្បាតកូវីដ-១៩ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានកំណើនថេរ ជាង ៧% ជារៀងរាល់ឆ្នាំ អស់រយៈពេលជាង ២ទសវត្សរ៍ ជាមួយនឹងអត្រាកំណើន ៦% នៅឆ្នាំ២០២៤។ គួរកត់សម្គាល់ថា ប្រទេសកម្ពុជា រួមជាមួយប្រទេសសេណេហ្គាល់ (Senegal) ត្រូវបានអង្គការសហប្រជាជាតិអនុម័តឯកភាពសម្រាប់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៩។

៥. ករណី ស៊ុន ចន្ធី

កាលពីខែធ្នូឆ្នាំមុន សាលាដំបូងរាជធានីភ្នំពេញបានកាត់ទោសលោក ស៊ុន ចន្ធី អតីតប្រធានគណបក្សប្រឆាំងនៃគណបក្សកម្លាំងជាតិ (PPP) ឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ និងពិន័យជាប្រាក់ចំនួនបួនលានរៀល (ប្រហែល ១,០០០ ដុល្លារ) ពី

បទញុះញង់បង្កចលាចលធ្ងន់ធ្ងរដល់សង្គម តាមរយៈការផ្សព្វផ្សាយព័ត៌មានមិនពិតតាមប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងចេតនាបំភាន់សាធារណជន។ តុលាការបានហាមជនជាប់ចោទ ស៊ុន ចន្ធី មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះបោះឆ្នោតអស់មួយជីវិត។

៦. សេរីភាពសារពត៌មាន និងការបញ្ចេញមតិៈ

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យមានការរីកចំរើនគួរឱ្យកត់សម្គាល់ និងសម្រេចបាននូវព្រឹត្តិការណ៍សំខាន់ៗជាច្រើនក្នុងការជំរុញការទទួលបាននូវសិទ្ធិមនុស្សសម្រាប់ប្រជាជនរបស់ខ្លួន។ សេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ គឺជាសសរស្តម្ភគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ។ ប្រទេសកម្ពុជារក្សាបាននូវជំហរបើកទូលាយចំពោះសេរីភាពទាំងនេះ និងដែលត្រូវបានការពារដោយច្បាប់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិដែលកម្ពុជាជាហត្ថលេខី។ ទាំងនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងការលើកកម្ពស់សិទ្ធិមនុស្ស និងនីតិរដ្ឋ ដូចមានចែងក្នុងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ។ រដ្ឋាភិបាលកម្ពុជាគាំទ្រសេរីភាពនៃការបញ្ចេញមតិ ប៉ុន្តែត្រូវតែអនុវត្តច្បាប់ប្រឆាំងនឹងបុគ្គលដែលបំភ្លៃការពិត ធ្វើការចោទប្រកាន់មិនពិត និងបង្កើតភាពចលាចលក្នុងសង្គមដោយមានចេតនាបំភាន់សាធារណជន។ សកម្មភាពបែបនេះបានគំរាមកំហែងយ៉ាងខ្លាំងដល់សន្តិភាព ស្ថិរភាព និងសុខុមាលភាពសេដ្ឋកិច្ចរបស់ប្រទេស និងមិនត្រូវបានការពារក្រោមគោលការណ៍សេរីភាពនៃការបញ្ចេញមតិទេ ។ អាជ្ញាធរកម្ពុជាបានចាត់វិធានការចំពោះអ្នកដែលបំពានច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសប៉ុណ្ណោះ។

យោងតាមក្រសួងព័ត៌មានកម្ពុជា អ្នកសារព័ត៌មានប្រមាណ ១ម៉ឺននាក់ និងបណ្តាញសារព័ត៌មានជាង ២០០០ កំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជា ។ របាយការណ៍ថ្មីមួយដែលមានចំណងជើងថា "ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា" ដែលបានបោះពុម្ពផ្សាយក្នុងខែមេសា ឆ្នាំ២០២៤ ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា តាមរយៈការយល់ឃើញពីសំណាក់អ្នកសារព័ត៌មានអាជីព។ ការស្ទង់មតិបានបង្ហាញថា ៧៩.៨% នៃអ្នកឆ្លើយសំណួរ សរុបចំនួន ៣៤១ នាក់ បានវាយតម្លៃល្អអំពីសេរីភាពសារព័ត៌មាននៅកម្ពុជា ដោយក្នុងនោះមាន ៧១% វាយតម្លៃថា "ល្អ" និង ៨.៨% វាយតម្លៃថា "ល្អណាស់" ។ ការសិក្សាក៏បានរកឃើញថា ៩៥% នៃអ្នកឆ្លើយសំណួរបានយល់ស្របថា ភាពចម្រុះនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជានាពេលបច្ចុប្បន្នបានរួមចំណែកដល់ការលើកកម្ពស់សេរីភាពសារព័ត៌មាន។

៧.ទំនាក់ទំនងទ្វេភាគី កម្ពុជា-ជប៉ុនៈ

ស្តីពីទំនាក់ទំនងទ្វេភាគី ឆ្នាំ ២០២៥ នេះ គឺខួបទី ៧២ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងជប៉ុន ដែលពីមួយឆ្នាំទៅមួយឆ្នាំកាន់តែមានភាពរឹងមាំ និងរីកលូតលាស់បន្ថែមទៀត ។ នៅក្នុងសារលិខិតអបអរសាទររបស់ **សម្តេច** ទៅកាន់ **នាយករដ្ឋមន្ត្រី Shigeru Ishiba** នៅថ្ងៃទី០១ ខែតុលា ឆ្នាំ ២០២៤ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** បានលើកឡើងពីចំណងមិត្តភាពដ៏ល្អប្រសើរ និងទំនាក់ទំនងទ្វេភាគីដ៏ជិតស្និទ្ធ ដែលប្រទេសទាំងពីរទទួលបាន ក្រោមការផ្តួចផ្តើមអោយមានការផ្លាស់ប្តូររវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ប្រទេសទាំងពីរជាញឹកញាប់ និងកិច្ចសហប្រតិបត្តិការជាក់ស្តែងក្នុងវិស័យជាច្រើន។ ភាគីទាំងពីរបានអះអាងសារជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាក្នុងការពង្រឹងបន្ថែមទៀតនូវភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាវាយតម្លៃខ្ពស់ចំពោះការរួមចំណែកដែលមិនអាចខ្វះបានរបស់ប្រទេស

ជប៉ុនក្នុងដំណើរការសន្តិភាព ការស្តារឡើងវិញ និងការគាំទ្រជាបន្តបន្ទាប់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់ព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនេះ តាមការអញ្ជើញរបស់រដ្ឋាភិបាលជប៉ុន **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** និង **លោកជំទាវបណ្ឌិត** នឹងអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការការងារ នៅប្រទេសជប៉ុន ចាប់ពីថ្ងៃទី ២៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០២៥ ខាងមុខនេះ ។ ដំណើរទស្សនកិច្ចនេះនឹងជំរុញបន្ថែមទៀតនូវភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរបស់ប្រទេសទាំងពីរ ព្រមទាំងធ្វើឱ្យស៊ីជម្រៅនិងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យដែលមានផលប្រយោជន៍ទៅវិញទៅមក។

សូម ឯកឧត្តម មេត្តាទទូលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ហត្ថលេខា

ទុយ រី